# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៥ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា ១.-**

បង្កើតយន្តការចុះបញ្ជីសំណើវិនិយោគ ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" និងផ្ដល់ការលើកទឹកចិត្ត នៅរាជធានី-ខេត្ត ដែលមានឈ្មោះថា **អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត "អ.គ.វ.រ.ខ"** ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- | អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | ប្រធាន |
| ២- | អភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | អភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្ត | អនុប្រធាន |
| ៤- | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធាន |
| ៥- | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ៧- | ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៨- | ប្រធានមន្ទីររ៉ែ និងថាមពល | សមាជិក |
| ៩- | ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ១០- | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១- | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១២- | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១៣- | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤- | ប្រធានមន្ទីរផែនការ | សមាជិក |
| ១៥- | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១៦- | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ១៧- | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៨- | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩- | តំណាងសាខាគយ និងរដ្ឋាកររាជធានី-ខេត្ត | សមាជិក |
| ២០- | តំណាងសាខាពន្ធដាររាជធានី-ខេត្ត | សមាជិក |
| ២១- | តំណាងលេខាធិការដ្ឋាន | លេខាធិការ ។ |

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីប្រធានអវត្តមាន ។

**អ.គ.វ.វ.ខ** អាចអញ្ជើញតំណាង ឬ មន្ត្រីជំនាញពីក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ទីរ អង្គភាពពាក់ព័ន្ធ អភិបាលរង នៃគណៈអភិបាលរាជធានី-ខេត្ត និង រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចូលរួមក្នុងកិច្ចប្រជុំ តាមការចាំបាច់ ។

**មាត្រា ២.-**

**អ.គ.វ.វ.ខ** ត្រូវមានលេខាធិការដ្ឋានមួយ សម្រាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ខ្លួន ដឹកនាំដោយ អនុប្រធានអចិន្ត្រៃយ៍ នៃ **អ.គ.វ.វ.ខ** ។

**អ.គ.វ.វ.ខ** មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រាដោយឡែក សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន ។

**មាត្រា ៣.-**

**អ.គ.វ.វ.ខ** ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគ ជា គ.ល.គ និងការផ្តល់ការលើកទឹកចិត្ត ចំពោះគម្រោងដែលមានទុនវិនិយោគទាបជាង ៥ (ប្រាំ) លានដុល្លារអាមេរិក ។

**មាត្រា ៤.-**

**អ.គ.វ.វ.ខ** ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹង គ.ល.គ មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ។

**មាត្រា ៥.-**

គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ អង្គភាពក្នុងរាជធានី-ខេត្ត ជាខ្សែបណ្តោយរបស់ខ្លួន នូវសិទ្ធិសម្រេចក្នុងនាមក្រសួង-ស្ថាប័ន ដោយត្រូវចេញបទប្បញ្ញត្តិណែនាំលម្អិតដល់មន្ទីរ អង្គភាព និងមន្ត្រីក្រោមឱវាទស្តីពីកិច្ចដំណើរការ និងនីតិវិធី ដែលត្រូវអនុវត្តចំពោះកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាបណ្ណ ការយល់ព្រមនានាក្នុងនាមក្រសួង-ស្ថាប័នរបស់ខ្លួន ។

**មាត្រា ៦.-**

គម្រោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសម្រេចក្នុងការចុះបញ្ជីសំណើវិនិយោគ និង ការផ្តល់ការលើកទឹកចិត្តរបស់ **អ.គ.វ.វ.ខ** ទេ ដោយត្រូវឆ្លងតាមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷

១- គម្រោងវិនិយោគមានទំហំទុនវិនិយោគចាប់ពី ៥ (ប្រាំ) លានដុល្លារអាមេរិកឡើងទៅ

២- គម្រោងវិនិយោគដែលមានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់រាជធានី-ខេត្ត ចាប់ពី ២ (ពីរ) ឡើងទៅ

៣- គម្រោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស

៤- គម្រោងវិនិយោគស្ថិតក្រោមច្បាប់ស្តីពីសម្បទាន និង យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

៥- គម្រោងវិនិយោគដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទ្រព្យសម្បត្តិរដ្ឋ

៦- គម្រោងវិនិយោគដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន ប៉ះពាល់ដល់សន្តិសុខជាតិ មានវេទយិតភាពខាងនយោបាយ ប៉ះពាល់ដល់ការងារអភិរក្ស និង ការពារសម្បត្តិវប្បធម៌ជាតិ

៧- គម្រោងវិនិយោគពាក់ព័ន្ធនឹងការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៨- គម្រោងវិនិយោគដែលស្ថិតនៅក្នុងបញ្ជីអវិជ្ជមានដែលនៅជាធរមាន

៩- គម្រោងវិនិយោគ ដែលមានវេទយិតភាពផ្សេងៗ ដែលនឹងត្រូវកំណត់ដោយឡែកក្នុងប្រកាសរួម រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៧.-**

**អ.គ.វ.រ.ខ** ជាយន្តការ “ច្រកចេញ-ចូលតែមួយ” លើការងារវិនិយោគនៅក្នុងរាជធានី-ខេត្ត ។

**អ.គ.វ.រ.ខ** ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ជាធរមាន ដូចដែលអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ។

**មាត្រា ៨.-**

គម្រោងវិនិយោគទាំងឡាយ ដែលត្រូវបានចុះបញ្ជី និង ទទួលបានការលើកទឹកចិត្តដោយអនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤, ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យនានា ត្រូវបន្តឋានៈជា **គ.ល.គ** នៅក្រោយអនុក្រឹត្យនេះចូលជាធរមាន ។

គម្រោងដែលមានទុនវិនិយោគទាបជាង ៥ (ប្រាំ) លានដុល្លារអាមេរិក អាចស្នើសុំចុះបញ្ជីនៅ **អ.គ.វ.រ.ខ** ដោយស្ម័គ្រចិត្ត និង ដោយមានការឯកភាពពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវចេញបទប្បញ្ញត្តិស្តីពីការណែនាំអនុវត្តជាក់ស្តែង និងធ្វើការបណ្តុះបណ្តាលមុខជំនាញដល់ **អ.គ.វ.រ.ខ** តាមសមត្ថកិច្ចរៀងៗខ្លួន ដើម្បីធានាឱ្យដំណើរការនៃយន្តការនេះប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

**អ.គ.វ.រ.ខ** ត្រូវធ្វើរបាយការណ៍ជាប្រចាំ ផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

**អ.គ.វ.រ.ខ** ត្រូវអនុវត្តការងារ បន្ទាប់ពីគ្រប់ក្រសួង-ស្ថាប័នបានធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ អង្គភាព ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ និងបន្ទាប់ពីមានសេចក្តីសម្រេច ឬ លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលរាជធានី-ខេត្ត ក្នុងការបង្កើត **អ.គ.វ.រ.ខ** រៀងៗខ្លួន ។

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈ-អភិបាលរាជធានី-ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

Sean B. Thin

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ជិន ប៊ុនស៊ាន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម សម្តេចពិជ័យសេនា ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ